# ពាក្យឃោសនាដែលនិយាយថា "សីហនុហើយនិងលន់_នល់ចែកផ្លូវគ្នាដើរ !!"

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១០ កក្កដា ២០០៥

ខ្ញុំសូមធ្វើការសិក្សាប្រៀបធៀបរវាងអត្ថបទពីរ, មួយជារបស់សម្ដេចសីហនុ មួយទៀតជារបស់ខ្ញុំ គឺរបៀបដូចជាគេចាក់គម្ពីរដូច្នោះឯង ហើយស្រាប់តែខ្ញុំឃើញថា គម្ពីររបស់ខ្ញុំហើយនិងគម្ពីររបស់សម្ដេចសីហនុ«ចាវគ្នា»... ពោលគឺអត្ថបទទាំងពីរ បានធ្វើឲ្យ«ខ្ទាក់»ចេញពាក្យឃោសនាមួយ ដែលបានផ្សាយនៅគ្រប់ទីកន្លែង នៅតាមផ្លូវរាជធានីភ្នំពេញនៅខែធ្នូឆ្នាំ១៩៦៩ ហើយដែលមានសេចក្ដីថា ៖

«សម្ដេចសីហនុហើយនិងឧត្ដមសេនិយលន់-នល់ មានគោលការណ៍តែមួយដូចគ្នា (គឺដេញយួន) ប៉ុន្តែដើរផ្លូវផ្សេងគ្នា» ។ គឺពាក្យឃោសនានេះហើយ ដែលបានញ៉ាំងឲ្យឧត្ដមសេនិយលន់-នល់ និងប្រជាពលរដ្ឋខ្មែរនៅភ្នំពេញចាញ់ល្បិចកលរបស់សីហនុ ដោយហ៊ានងើបឡើងបះបោរប្រឆាំងនឹងវត្តមានយៀកកុងនៅប្រទេសកម្ពុជា... ថ្វីបើពួកយើងទាំងអស់គ្នាដឹងថា ការអនុញ្ញាតតាំងទ័ពយៀកកុងនៅក្នុងទឹកដីខ្មែរ ជានយោបាយរបស់ស្ដេចយ៉ាងណាក្ដី ។ កាលនោះខ្មែរយើងទាំងអស់គ្នាមានជំនឿថា ស្ដេចសីហនុបញ្ជាឲ្យលោកលន់-នល់ដេញយួនពីខាងក្នុង ចំណែកព្រះអង្គវិញទៅដេញយួនពីខាងបរទេស ។ គ្មាននរណាម្នាក់នឹកស្មានថា សម្ដេចព្រះបិតាជាតិ ព្រះអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើម, ព្រះមហាវិរក្សត្រ ប្រែខ្លួនទៅជាជនក្បត់ ហើយបែរជារត់ចូលយៀកកុងទៅវិញ ដោយបានឆ្លៀតឱកាសចាក់សម្លាប់ឧត្ដមសេនិយលន់-នល់ និងប្រជាពលរដ្ឋខ្មែរពីក្រោយខ្នង ។

តទៅនេះជាអត្ថបទរបស់ស្ដេចសីហនុនៅក្នុង<វែបសាយ>របស់ទ្រង់ ៖ **Mon 2ème texte pour le 13 juin 2004 - Le Calice jusqu'à la lie - Première partie Chapitre 10 - Nixon sauve Lon Nol;... La duperie du programme Khmer Rouge; Mao soutient le Funk...**

«និចសុនជួយសង្គ្រោះលន់-នល់

«ខែឧសភា១៩៧០ ជាខែសំបូរទៅដោយព្រឹត្តិការណ៍ធំៗជាច្រើនពេកណាស់ ។ ខែនោះបានចាប់ផ្តើមឡើង ដោយមានព្រឹត្តិការណ៍រន្ធះបាញ់មួយ ដែលបណ្ដា-លឲ្យពិភពលោកមានការភ្ញាក់ផ្អើលញាប់ញ័រ ព្រមទាំងបណ្ដាលឲ្យមានការបែកបាក់នៅក្នុងមតិសាធារណជននៃប្រជាជាតិអាមេរិកាំង ឲ្យមានការដាច់រហែកចេញពីគ្នា តាមផ្លូវសិលធម៌និងចិត្តសាស្ត្រ ដែលមានភាពធ្ងន់ធ្ងរខ្លាំងឡើងៗ ជារៀងរហូតនៅក្នុងខែឆ្នាំកន្លងមក ។

«ក្នុងឆ្នាំ១៩៧៩, នៅប៉េកាំង, លោកហែនរី-គីស្សីងគ្ញើរនិងខ្លួនខ្ញុំ, ដោយយើងបានក្លាយទៅជា«ជនចូលនិវត្តន៍»នៃនយោបាយទាំងពីរនាក់, យើងក៏បានធ្វើការជួបគ្នាជាលើកដំបូងបំផុត, ដោយសារតែមាន«ការសំរួលរៀបចំ» ពីសំណាក់មិត្តភក្តិរួមរបស់យើង គឺពួកមេដឹកនាំនៃសាធារណរដ្ឋប្រជាមានិតចិន ។ ខ្ញុំក៏បានធ្វើការរំឭកដល់គូសន្ទនាអាមេរិកាំងរបស់ខ្ញុំ អំពីព្រឹត្តិការណ៍រន្ធះបាញ់នៃថ្ងៃទី១ឧសភា១៩៧០ របស់លោកប្រធានាធិបតីនិចសុន (ដែលមានគីស្សីងគ្ញើរជាព្រះរាជគ្រូ ÷ l'éminence grise), គឺអន្តរាគមន៍ពួកយោធាអាមេរិកាំង ដើម្បីទៅជួយលន់-នល់និង«បន»វា ដើម្បីឲ្យពួកនេះចៀសផុតរួចពីការដួលរលំយ៉ាងច្បាស់ប្រាកដ ។ ប្រសិនបើគេបណ្ដោយឲ្យពួកនេះដួលរលំទៅ, រូបខ្ញុំច្បាស់ជាអាចវិលត្រឡប់ទៅប្រទេសកម្ពុជា ដើម្បីទៅស្តារសភាពការណ៍មរណៈដ៏អស់សង្ឃឹម ក្នុងប្រការជួយស្រោចស្រង់ប្រទេសយើងផង និងជួយដល់គោលជំហររបស់សហរដ្ឋអាមេរិកនៅឥណ្ឌូចិនផង, ពីព្រោះកាលសម័យនោះ ពួកខ្មែរក្រហមនៅមានចំនួនតិចតួចចំណែកពួកចិននិងពួកវៀតណាមខាងជើងវិញ បន់ឲ្យតែរាជាណាចក្រកម្ពុជា វិលត្រឡប់ទៅរក«សភាពដើម»វិញតែប៉ុណ្ណោះ ។

«លោកគីស្សីងគ្ញើរក៏បានឆ្លើយតបមកខ្ញុំវិញថា គាត់ក៏ដូច្នោះដែរ ចង់ឲ្យលន់-នល់ដួលរលំ ហើយចង់ឲ្យសីហនុត្រឡប់វិលវិញ, ក៏ប៉ុន្តែគាត់បានយល់ថា ពួករដ្ឋប្រហារនៅភ្នំពេញហើយនិងខ្លួនខ្ញុំ តាមពិតទៅសុទ្ធសឹងតែជាពួកគូកនដែលឃុបឃិតត្រូវរ៉ូវគ្នា ដើម្បីលេងល្បែងកំប្លុកកំប្លែង «ការទម្លាក់រូបខ្ញុំពីមុខតំណែង» ក្នុងប្រការបោកបញ្ឆោតពួកយៀកកុងនិងពួកយៀកណាមខាងជើង ។ ខ្ញុំក៏បានសារភាពទៅឥស្សរជនអាមេរិកាំងរូបនេះ (គីស្សីងគ្ញើរ) ថារឿងរបស់គាត់មិនអាចឲ្យយល់បានទាល់តែសោះ សំរាប់បញ្ញាញាណដ៏ទន់ខ្សោយរបស់ខ្ញុំ ។

«ទោះជាយ៉ាងណាក៏ដោយ, ខ្ញុំចេះតែនៅគិតថា ប្រសិនបើលោកប្រធានាធិបតីនិចសុន មានលទ្ធភាពអាចទស្សន៍ទាយមើលអនាគតជាមុនបាន ដូច «Madame Soleil» ឬលោក Jean Viaud, លោកច្បាស់ជាមិនសំរេចចិត្តធ្វើអន្តរាគមន៍ជួយសង្គ្រោះមួយ ដែលក្នុងរយៈពេលពីរបីឆ្នាំក្រោយមក បានក្លាយទៅជា«អត្តឃាតនយោបាយ» ដែលប្រកបដោយសេចក្តីអាម៉ាស់ថោកទាបនៃប្រជាជាតិអាមេរិកាំង»

★★★ ដើម្បីគោរពសេចក្ដីពិតនៃប្រវត្តិសាស្ត្រ គេគួររំឭកថា លោកប្រធានាធិ

បតីនិចសុន ដែលបានសំរេចបញ្ជាឲ្យមានអន្តរាគមន៍នៃកងទ័ពអាមេរិកាំងនៅថ្ងៃទី១៧សភា១៩៧០ គឺមិនមែនសំរាប់ជួយសង្គ្រោះរបបលន់-នល់ ឬក៏ជួយសង្គ្រោះប្រទេសខ្មែរ នៅចំពោះមុខការវាយប្រហាររបស់យៀកកុងនោះទេ តែគឺធ្វើឡើងសំរាប់ជួយកងទ័ពអាមេរិកាំង ឲ្យថយចេញពីវៀតណាមដោយកិត្តិយស ! ។ ទោះជាយ៉ាងណាក៏ដោយ, អន្តរាគមន៍របស់កងទ័ពអាមេរិកាំង ដែលឆ្លងកាត់ទឹកដីកម្ពុជា តែចំនួន២០គ.ម. ចូលខាងក្នុងដីខ្មែរ ក្នុងរយ:ពេលតែ២ខែ គឺបានលទ្ធផលចុងចប់ ដេញកងទ័ពយៀកកុងឲ្យចូលយ៉ាងជ្រៅទៅក្នុងប្រទេសកម្ពុជា ដល់ខេត្តកណ្តាល (ស្អាង-គគីរធំ) ដល់ខេត្តកំពង់ធំ-សៀមរាប-បាត់ដំបង... ហើយនៅក្នុងពេលជាមួយគ្នានោះ ក៏បានបញ្ជូនកងទ័ពយៀកណាមខាងត្បូងរាប់ម៉ឺននាក់ ទៅដុតភូមិករផ្ទះសំបែង ប្លន់រឹបអូសប្រជាពលរដ្ឋខ្មែរ រំលោភស្រីភេទនៅតាមភូមិភាគខាងកើត... ជាហេតុឲ្យប្រជាពលរដ្ឋខ្មែររាប់សែននាក់ រត់ចូលក្នុងជួរខ្មែរក្រហម ។ សង្គ្រាមអាមេរិកាំង-យួន ជាសង្គ្រាមពង្រីកទឹកដីទេតើ !!...ទាំងនេះ គឺជាលទ្ធផលនៃនយោបាយឆ្កួតលីលារបស់ស្តេចសីហនុ ដែលភ្លេចទង្វើនិងពាក្យសំដីរបស់គាត់ទាំងអស់ ពោលគឺភ្លេចថា គឺខ្លួនគាត់នោះហើយ ដែលបានស្រែកអំពាវនាវឲ្យលោកគីស្សីងគ្មើរ មកទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា តាំងពីថ្ងៃទី១៨មិនា១៩៦៩ ។ តាំងពីថ្ងៃនោះរហូតដល់ខែមេសា១៩៧០ គឺ១៤ខែក្រោយមក, ដោយលោកឧត្តមសេនិយលន់-នល់ពុំបានធ្វើអ្វីទាំងអស់, ការឃុបឃិតរបស់ស្តេចសីហនុនិងគីស្សីងគ្មើរ «បានបណ្តាលឲ្យមានកិច្ចប្រតិបត្តិការទម្លាក់គ្រាប់បែកអាមេរិកាំង ដោយយន្តហោះ B-52 ចំនួន៣,៦៣០ដង ទៅលើទឹកដីប្រទេសកម្ពុជា» ។




(In the fourteen months the following the commencement of the bombingd in March 1969, the

**United States conducted 3,630 B-52 bombing raids in Cambodian territory» THE FLAWED ARCHITECT, Henry Kissinger and American Foreign Policy- by Jussi Hanhimäki, Oxford University Press- New York- p.44)** ។

ដូច្នេះតាំងពីថ្ងៃ១៨មិនា១៩៦៩ រហូតដល់ខែមេសា១៩៧០, ដោយលោកឧត្តមសេនិយលន់-នល់ និងអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈពុំបានធ្វើអ្វីទាំងអស់ វាមានការពិឃាតរង្គាលរួចទៅហើយ ទៅដល់ប្រជាពលរដ្ឋខ្មែរនៅព្រំប្រទល់ ដោយគ្រាប់បែកនៃយន្តហោះ **B-52** របស់សហរដ្ឋអាមេរិក ។ បូករួមសេចក្តីទៅ រឿងកំប្លុកកំប្លែងដ៏មហាអន្តរាយនៃ«ការទម្លាក់ស្តេចសីហនុ» គឺបានរៀបចំឡើងដោយស្តេចសីហនុខ្លួនឯងសោះ ជាមួយផាំ-យ៉ាំងដុង ហើយនិងលោកហែនរី-គីស៊្សីងគ្ញ័រ...។ រួចហើយពួកគេក៏យកឧក្រិដ្ឋកម្មដ៏មហាបិសាចនេះ (ពីព្រោះជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្មែរ) យកទៅលាបប្រឡាក់ លើរូបលោកឧត្តមសេនិយលន់-នល់ ។

⌘

⌘ ⌘

★★★ តទៅនេះ គឺជាអត្ថបទឯកសាររបស់ខ្ញុំផ្ទាល់... ការសន្ទនាជាមួយលោកថោង-លឹមហួង, សហការីម្នាក់របស់លោកឧត្តមសេនិយលន់-នល់ នៅខែធ្នូ១៩៦៩ គឺបីខែមុនព្រឹត្តិការណ៍នៃ«ថ្ងៃ១៨មិនា១៩៧០» ដែលបង្ហាញថា... នយោបាយរបស់ខ្មែរយើងងើបឡើងដេញយួនឈ្លានពាន ព្រមទាំងបញ្ជាឲ្យឧត្តមសេនិយលន់-នល់ដើរផ្លូវផ្សេង (ឲ្យទៅចូលអាមេរិកាំង), ចំណែកខ្លួនឯងដើរផ្លូវផ្សឹង (ទៅចូលប៉េកាំង) ដើម្បីបោកបញ្ឆោតយួន គឺជាទង្វើរបស់ស្តេចសីហនុទាំងអស់ (អត្ថបទដកស្រង់ចេញពីសៀវភៅសិក្សាស្រាវជ្រាវ ÷ **Cambodge- Le Chemin de l'Apocalypse- 350 pages)**

«ថោង-លឹមហួង»

«ខ្ញុំបានទៅផ្ទះមិត្តភក្តិខ្ញុំម្នាក់ឈ្មោះថោង-លឹមហួង (ដែលថ្ងៃក្រោយមកក្លាយទៅជា អនុរដ្ឋលេខាធិការប្រសួងឃោសនាការនៃរដ្ឋាភិបាលសាធារណរដ្ឋរបស់ឧត្តមសេនិយលន់-នល់) នៅសង្កាត់ទឹកល្អក់ នៅសប្តាហ៍ដំបូងនៃខែធ្នូឆ្នាំ១៩៦៩ ។

ប្រសិនបើនរណាម្នាក់ចង់ដឹងពីគោលប្រាថ្នាដ៏ក្រាស់ឃ្មឹកចាក់មិនធ្លុះរកយល់មិនបាន ដែលជាកម្លាំងរបស់ឧត្តមសេនិយលន់-នល់ក្នុងសម័យនោះ គេត្រូវទៅធ្វើការស្ទាបស្ទង់នៅផ្ទះប្អូនរបស់គាត់ គឺលោកវរសេនិយ៍ត្រីលន់-ណុន ។ ខ្ញុំបានមកលេងផ្ទះ ថោង-លឹមហួង គឺនៅក្នុងគោលបំណងនេះឯង ដោយហេតុថា ហួងកំពុងតែបំរើចៅហ្វាយនាយថ្មីរបស់ខ្លួន គឺលោកលន់-ណុន ក្នុងឋានៈជាសកម្ម-

ជនសម្ងាត់ម្នាក់នៅក្នុងកាសែត«ប្រយោជន៍ខ្មែរ»របស់លោកលឿង-វ៉ែន ហើយដែលថៅហ្វាយនាយពិតប្រាកដ គឺគ្មាននរណាក្រៅពីប្អូនរបស់លោកឧត្តមសេនិយអគ្គមេបញ្ជាការកងទ័ពនោះឯង ។

⌘

ថោង-លឹមហួង (ពេលនោះអាយុ៣០ឆ្នាំ គឺច្រើនជាងខ្ញុំ៣ឆ្នាំ) ចាក់ទឹកមួយកែវហុចមកឲ្យខ្ញុំ ៖

- គ្នាសប្បាយចិត្តណាស់ បានខ្លួនមកលេង, គ្នាមិនសង្ឃឹមថា ប៉ូលិនឯងមកលេងទេ (ហួងពោលដោយសម្លេងទន់ភ្លន់ ពោរពេញដោយមិត្តភាព)...

- ខ្ញុំសូមទោសចុះ ដែលក្រុបានមកលេងហួងឯង, ខ្ញុំឆ្លើយតប ។ តាំងពីត្រឡប់មកពីស្រុកបារាំងវិញ ខ្ញុំជាប់ដៃមមាញឹកខ្លាំងពេក រកដក់ឃ្លាមិនរួច...

- តើឯកឧត្តមស៊ឹម-វ៉ារសុខសប្បាយជាទេឬ ?

- សុខសប្បាយទេ ។ លោកអុំនឹកខ្លួនច្រើនណាស់... គាត់និយាយល្អតែពីហួងឯងទេ... ក៏ប៉ុន្តែជាមួយ ជូ-ថានី វិញ គាត់ហាក់ដូចជានៅមានគំនុំ ។

- ម៉េចទៅ... កាសែត«ខ្មែរឯករាជ្យ»បិទទ្វារ (ថោង-លឹមហួង ជាអតីតចាងហ្វាងការផ្សាយរបស់«ខ្មែរឯករាជ្យ»)...ឯកឧត្តមស៊ឹម-វ៉ារមិនពិបាកចិត្តខ្លាំងពេកទេឬ ?

- និយាយមិនពិបាក... ខ្ញុំមានអារម្មណ៍ថា លោកអុំស៊ឹម-វ៉ារកំពុងតែមានការល្វឹងជូរចត់ខ្លាំងណាស់ ។ គាត់ហាក់ដូចជាត្រូវគេបោះបង់ចោលគ្រប់ទិសទី ។ គ្នាយល់ថា លោកអុំកំពុងតែធ្វើការដកថយពីជីវិតនយោបាយទាំងស្រុងហើយពេលនេះ...

- ប៉ូលិនឯងនឹកស្មានថា មនុស្សដូចឯកឧត្តមអាចធ្វើអ្វីទៀតបាន ក្រៅតែពីការធ្វើនយោបាយ ។ ម្យ៉ាងវិញទៀត គ្មាននរណាអាចដឹងជាមុនបានទេ...អ្វីៗក៏មានការភ័ន្តប្រែដែរ ។ ថ្ងៃនេះ គាត់លេចឡើងជាជនក្បត់... ថ្ងៃស្អែកគាត់អាចក្លាយជាវិរបុរស...

- ហួង ! ខ្លួនធ្លាក់ចូលក្នុងការបកស្រាយវែងឆ្ងាយហួសពេកទេដឹង ។ លោកស៊ឹម-វ៉ារមិនដែលចង់ធ្វើវិរបុរសពីកាលណាទេ ក្នុងរឿងនេះខ្លួនដឹងច្បាស់ណាស់

- គ្នាបានទទួលដំណឹងថា ខ្លួនចង់បង្កើតកាសែតមួយថ្មីមែនទេ ?

- រឿងហ្នឹងមែន !

- ខ្លួនគិតដាក់ឈ្មោះអីដែរ ?

- ខ្ញុំយករឈ្មោះតាមកាសែត «Le Monde» ប៉ុន្តែស្តាប់ជាភាសាខ្មែរទៅ ដូចជាមិនសូវពិរោះសោះ ។ ម៉្លោះហើយ ពេលត្រឡប់មកពីលេងអង្គរវត្ត... ខ្ញុំក៏បែកគំនិតដាក់ឈ្មោះថា «នគរធំ» ដោយមានរូបព្រហ្មមុខបួន ជានិមិត្តរូបនៃអ្នកសង្កេតការណ៍ កំពុងដើរវិភាគពីគ្រប់ជ្រុងជ្រោយនៃទិសទាំង៤ ។

- ម៉្យាងដែរ (ថោង-លឹមហួងលាន់មាត់) ។
- ហួង ! (ខ្ញុំពោលដោយគំហុកមួយរំពេជ) ខ្ញុំមកនេះត្រូវការឲ្យខ្លួនជួយ...ខ្ញុំត្រូវការឲ្យខ្លួននិយាយការពិតប្រាប់ខ្ញុំទាំងអស់ កុំឲ្យមានសល់...
- គ្នាចាំតែជួយទេតើ !
- ឥឡូវនេះ ខ្លួនជាអ្នកជិតដិតជាមួយលោកលន់-ណុន ។ ខ្លួនអាចប្រាប់ខ្ញុំឲ្យត្រង់ៗ ឲ្យនៅៗតែម្ដងបានទេ... តើគោលជំហរពិតប្រាកដរបស់លោកឧត្ដមសេនិយជាមួយនឹងសម្ដេចយ៉ាងណាដែរ ? ឥឡូវនេះ នៅតាមផ្លូវមានគេនិយាយគ្រប់គ្នាពីរដ្ឋប្រហារ ។ ហើយអ្នកដែលដើរផ្សាយរឿងដូច្នេះ ទំនងដូចជាគ្មានភ័យព្រួយបារម្ភទាល់តែសោះ ម៉្យាងវិញទៀត ក៏ដូចជាគ្មាននរណាឈឺក្បាលហាលថ្ងៃអំពីរឿង«ខ្យល់ព្យុះកំបុតត្បូង»បែបដូចនេះផងដែរ ។ ធ្វើមើលតែរឿងសាមញ្ញធម្មតា ឬក៏ជារឿងកំប្លុកកំប្លែងស្មោះ !
- ពាក្យចចាមអារាមអស់ទាំងនេះ គ្មានមូលដ្ឋានទេ ។ លោកធំ (លន់-នល់) នៅតែជាអ្នកបំរើស្មោះស្ម័គ្រជាមួយចៅហ្វាយ (សីហនុ) ដដែល ។ លោកធំចង់ឲ្យខ្មែរយើងទាំងអស់គ្នាងើបឡើងតស៊ូប្រឆាំងនឹងយួនឈ្លានពាន មិនមែនឲ្យប្រឆាំងជាមួយសម្ដេចនោះទេ ។ នៅក្នុងប្រការនេះ លោកធំបាននិយាយម៉ឺងម៉ាត់ដាច់ខាត... លោកធំគ្រាន់តែជាអ្នកទី២របស់ចៅហ្វាយប៉ុណ្ណោះ...
- ខ្ញុំក៏បានឮការបកស្រាយអីចឹងដែរ... ដែលនិយាយថា ទំនាស់រវាងឧត្ដម-សេនិយលន់-នល់ហើយនិងសម្ដេច គឺគ្រាន់តែជារឿងកំប្លែងប៉ុណ្ណោះ ។ តាមពិតពីរនាក់នេះធ្វើការចូលគ្នាទៅវិញសោះ ! ដូច្នេះបើតាមហួងឯង...ពីរនាក់នេះមានគោលការណ៍នយោបាយតែមួយ ហើយនយោបាយនេះ គឺចេញមកពីសម្ដេចសីហនុ ។ ដូច្នេះហួងឯងនិយាយប្រាប់ខ្ញុំបានទេ តើលោកឧត្ដមសេនិយមានបានទទួលបញ្ជាពីសម្ដេចឲ្យដោះលែងបញ្ញវ័ន្តឆ្វេងនិយម (កុម្មុយនិស្ត) បីនាក់ គឺលោកភួង-តុន, កេង-វ៉ាន់សាក់ និងចៅ-សៅ... ដែលសម្ដេចសីហនុខ្លួនឯង ជាអ្នកបញ្ជាឲ្យចាប់ដាក់គុកនោះឬទេ ?
- តាមពិត គឺអីចឹងហើយ ។ នៅគ្រប់បញ្ហាទាំងអស់ លោកធំគ្រាន់តែជាអ្នកទទួលបញ្ជារបស់សម្ដេចតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែក្នុងប្រការបញ្ញាជនទាំងបីនាក់នេះ... លោកធំប្រហែលជាបានធ្វើការដោះស្រាយ ដោយប្រើសមត្ថភាពរបស់លោកតែប៉ុណ្ណោះ ។ ប៉ុលិន រឿងនេះជារឿងនយោបាយជាន់ខ្ពស់... គ្នាមិនអាចនិយាយទៅឆ្ងាយលើសពីនេះបានទេ ។ គ្នាក៏មិនដឹងហួសពីខ្លួនដែរក្នុងរឿងនេះ ។
- ខ្ញុំក៏ដឹងថាជានយោបាយជាន់ខ្ពស់ដែរពួកម៉ាក ។ ខ្ញុំមិនមែនយករឿងទាំងអស់នេះ ទៅចុះផ្សាយក្នុងកាសែតទេ ។ ក៏ប៉ុន្តែខ្ញុំចង់យល់អំពីគន្លឹះសោរនៃអាថ៌កំបាំង...។ បូករួមសេចក្ដីទៅសម្ដេចបានតែងតាំងឧត្ដមសេនិយលន់-នល់ឲ្យធ្វើនយោបាយប្រូអាមេរិកាំងព្រមទាំងប្រឆាំងយួន, ពោលគឺឲ្យប្រឆាំងនឹងស្ដេច ។ ប្រសិន

បើនយោបាយប្រឆាំងនឹងសម្តេចសីហនុដូច្នេះ  បានត្រូវគ្រោងឡើងដោយស្នាដៃគ្រូឧបជ្ឈាយ៍នៃល្បិចកលកំពូលដ៏មហាក្រឡិចក្រឡុចឈ្មោះ ជានរោត្តម-សីហនុ គ្នាចង់ដឹងដែរថា តើសម្តេចមានគោលប្រាថ្នាចង់បានអ្វីពិតប្រាកដនោះ ។ លោកលន់-នល់ត្រូវតែដឹងរឿងនេះជាងយើង ។ ហួង ! គ្នាខ្លាចតែចូលអន្ទាក់របស់គេទេអ៊ើយ... ខ្លួនមានដឹងរឿងផ្កា១០០របស់ម៉ៅ-សេទុងឬទេ ? (<u>កកន</u> ៖ យុទ្ធនាការនៃ «បុប្ផ១០០» ជាចលនាបញ្ឆោតរបស់ប្រធានម៉ៅ ដើម្បីឲ្យបញ្ញាជនចិនងើបឡើង «ច្រួង» ដើម្បីគ្រាន់តែយកទៅសម្លាប់ចោលទាំងអស់គ្នា) ។ លោកស៊ឹម-វ៉ា់រ, ហួងឯងហើយនិងខ្ញុំ យើងគ្រាន់តែជាកូនជីងរបស់គេប៉ុណ្ណោះ... មិនស្រួលៗគេចាប់យកទៅបាញ់ចោល ដូចសៅ-ង៉ូយនៅត្រពាំងក្រឡឹងអីចឹងឯង...

– ប៉ូលិនឯងកុំនិយាយឲ្យជ្រុលហួស... លោកធំបានឲ្យបងណុនប្រាប់ពួកយើងថា លោកមានគោលជំហរស្មោះត្រង់គ្មានរង្គោះរង្គើចំពោះចៅហ្វាយ...

– បើដូច្នេះ មានតែលោកធំប្រឆាំងនឹងពួកយើង...

– មិនមែនអញ្ចឹងទេ ។ ដោយដោះលែងបញ្ញាជនទាំងបីរូប លោកធំបានជ្រើសរើសយកនយោបាយសេរីនិយម ។ គឺលោកធំធ្វើការឲ្យពួកយើង...

– រឿងនេះ ដូចជាមិនស្រួលទេហួង... ហើយគ្នាដូចកាន់តែលែងយល់តែម្តង ។ នៅពេលដែលសម្តេចដាក់ឲ្យមានស្ថានទូតអាមេរិកាំងឡើងវិញ... សម្តេចក៏ទទួលប្រមុខរដ្ឋយៀកកុង ង្វៀង-តាន់ផាត់ ជាផ្លូវការផងដែរ ។ មិនត្រឹមតែប៉ុណ្ណោះ សម្តេចបានបញ្ជូនយន្តហោះដាកូតាយោធា ទៅដឹកជននេះមកពីតំបន់មេមត់ ។ គឺជារឿងមួយគួរឲ្យហួសចិត្ត... ពីភពលោកទាំងមូលបានឃើញប្រមុខរដ្ឋខ្មែរ ទៅទទួលប្រមុខរដ្ឋយៀកកុងនៅពោធិចិនតុង ដែលជិះយន្តហោះយោធាខ្មែរ ចេញពីទឹកដីខ្មែរ ! តើនេះពុំមែនជារឿងលក់ជាតិទេឬ ? លើសពីនេះទៅទៀត សម្តេចបានបណ្តេញគណ:កម្មការត្រួតពិនិត្យអន្តរជាតិ ដោយយកលេសថា«អត់លុយ» ។ ហើយឥឡូវនេះ សម្តេចសប្បាយក្នុងការដោះលែងពួកភ្នាក់ងារយៀកកុង ដែលកងទ័ពយើងចាប់បានមកដោយលំបាក... ធ្វើមើលតែគេលែងសត្វចាបចេញពីទ្រុង ពីព្រោះព្រះអង្គចង់«បានមគ្គបានផល» ។ ហើយនេះ ខ្លួនប្រសិទ្ធិនាមថាជានយោបាយប្រឆាំងយួន ? ខ្ញុំសូមប្រាប់ខ្លួនត្រង់ទៅចុះ ថាខ្ញុំមិនទុកចិត្តសម្តេចសីហនុទេ ហើយខ្ញុំក៏មិនទុកចិត្តឧត្តមសេនីយ៍លន់-នល់ដូចគ្នាផងដែរ !...

– ប៉ូលិន... បើឯងទៅផ្ទះបងណុន ចៀសវាងដាច់ខាតកុំនិយាយប៉ះពាល់ស-ម្តេចឲ្យសោះ...

– ម្តេចបានជាអីចឹង ?

– បងណុនចង់ជួបខ្លួន... បន្តិចទៀតគាត់បញ្ជូនខួន-ថៃ (ចាងហ្វាងសារពត៌-មានសុវណ្ណភូមិ) ឲ្យទៅជួបខ្លួនជាមិនខាន...

ហើយថោង-លឹមហួង ក៏និយាយបន្តពីទ្រឹស្តីរបស់គាត់ ដែលបកស្រាយថា

សីហនុនិងលន់-នល់មានការត្រូវជងត្រូវផ្ដែជាមួយគ្នា ៖

- ខ្លួនមិនដឹងថា សម្ដេចបានបញ្ជាឲ្យលោកធំ ទៅត្រួតពិនិត្យព្រំដែនចំនួន២ឆ្នាំមកហើយទេឬ ? (ហួងពោល) ។

- ខ្លួនមិនឃើញថា សម្ដេចហ្នឹងស្រឡាញ់តែកងទ័ពយៀកកុង ដែលគាត់ដឹកគ្រឿងអាវុធនិងម្ហូបម្ហាយកទៅចំពោក... ចំណែកកងទ័ពខ្មែរវិញ គ្មានអី«អាំង»ជាមួយបាយកកទេ មានតែ«កងកាក»... (ខ្ញុំពោល) ។

- តែគ្នាសូមប្រាប់រឿងសម្ងាត់មួយចុះ... លោកធំបានប្រាប់បងណុនថា ចៅហ្វាយបានបញ្ជាឲ្យធ្វើបាតុកម្មដេញយួននៅក្នុងពេលឆាប់ៗនេះ ។ រឿងសម្ងាត់មួយទៀត ដែលគ្នាបានដឹងពីបងណុន... នៅសមាជខាងមុខនេះ ចៅហ្វាយរៀបចំរំលាយរដ្ឋាភិបាលស្រោចស្រង់ជាតិ... បើប្រការនេះមិនសំរេចទេ ទ្រង់នឹងរត់ទៅស្រុកបារាំង...

ពេលនោះខ្ញុំហួសចិត្ត ដូចគេដាល់ត្រូវចុងដង្ហើម ៖

- បើសម្ដេចអនុញ្ញាតឲ្យលោកធំរៀបចំធ្វើបាតុកម្មដេញយួន រឿងនេះគួរឲ្យជឿបានខ្លះ ពីព្រោះបងណុនបានពត៌មាននេះពីបងប្រុសរបស់គាត់ ។ តែរឿងដែលថា ចៅហ្វាយនាយចង់រំលាយ«រដ្ឋាភិបាលស្រេចស្រង់ជាតិ» ហើយបើមិនបានសំរេចទ្រង់នឹងរត់ទៅស្រុកបារាំង... តើបងណុនបានពត៌មានពីណាមក ? វាមានតែគាត់ត្រូវជើង ឬក៏បានរកស៊ីតថ្លៃគ្នាជាមួយនឹងពួកប្រែតអសុរកាយ )!!) វាមានតែគាត់បានដំណឹងបែបដូចនេះ ពី«ក្លង់»ខែក-វណ្ណី ? ។

ថោង-លឹមហួងញញឹមពព្រាយ ប៉ុន្តែមិននិយាយថាអ្វីទាំងអស់ ដែលជាសេចក្ដីបញ្ជាក់ថា ខ្ញុំបានយល់ត្រូវ ។ ប៉ុន្តែភ្លាមៗនោះ ខ្ញុំមិនសូវជាជឿប៉ុន្មានទេ អំពីរឿងបាតុកម្មដេញយួននេះផង ហើយនិងរឿងស្ដេចរត់ទៅបរទេសនោះផង ។ ខ្ញុំស្មានតែថោង-លឹមហួង ប្រឹងនិយាយបំបោងដើម្បីកំប្លែងលេងបន្ធូរបរិយាកាស ។

- ខ្លួនដឹងទេ, ប៉ូលិន (ថោង-លឹមហួងឲ្យយោបល់បន្ថែម) គ្នាយល់ថា ចៅហ្វាយហើយនិងលោកធំ មានយុទ្ធសាស្ត្រនយោបាយតែមួយដូចគ្នា តែដើរផ្លូវផ្សេងគ្នា (!!)...

⌘

⌘ ⌘

★★★ គឺពាក្យរបស់លោកថោង-លឹមហួងចុងក្រោយនេះហើយ ដែល«ចាវគ្នា»ជាមួយពាក្យរបស់សម្ដេចសីហនុក្នុងអត្ថបទខាងលើ ៖ «...ក៏ប៉ុន្តែគាត់ (ហែនរី-គីស្ស៊ីងគ្នើរ)បានយល់ថា ពួករដ្ឋប្រហារនៅភ្នំពេញ ហើយនិងខ្លួនខ្ញុំតាមពិតទៅសុទ្ធសឹងតែជាពួកគូកន ដែលឃុបឃិតត្រូវរ៉ូវគ្នា ដើម្បីលេងល្បែងកំប្លុកកំប្លែងនៃការ«ទម្លាក់រូបខ្ញុំពីមុខតំណែង»ក្នុងប្រការបោកបញ្ឆោតពួកយៀកកុងនិងពួកយៀកណាមខាងជើង»...

ហេ ! ហេ ! នៅចុងចប់ទៅ... គឺស្ដេចសីហនុទៅវិញសោះ ដែលស៊ីគ្រលុំជាមួយនិងគីស្ស៊ីងគ្ញើរ ដើម្បីលេងល្បែងបោកបញ្ឆោត ឲ្យឧត្តមសេនិយលន់-នល់ និងប្រជាជាតិខ្មែររត់ចូលអាមេរិកាំង ក្នុងគោលបំណងឲ្យយៀកកុងនិងយៀកណាមខាងជើងសម្លាប់ជាតិខ្មែរពីក្រោយខ្នង...

ខ្ញុំបានសិក្សាឯកសារជាច្រើននៃនយោបាយក្រៅប្រទេសរបស់ប្រទេសកម្ពុ-ជាសម័យនោះ (១៩៦៩) ពុំឃើញមានស្នាមឬសញ្ញាសូម្បីតែបន្តិចបន្តួចដែលថាលោកលន់-នល់បានក្បត់ជាតិ ឬក៏ក្បត់សីហនុដោយលក់ខ្លួនឲ្យអាមេរិកាំងនោះសោះ... តែបានឃើញតែស្ដេចសីហនុ ដែលស៊ីគ្រលុំឃុបឃិតមិនចេះចប់ជាមួយនិងគីស្ស៊ីងគ្ញើរ... ឬឃើញតែគីស្ស៊ីងគ្ញើរដែលស៊ីគ្រលុំមិនចេះចប់តែជាមួយនិងសីហនុ ដើម្បីកសាងឧក្រិដ្ឋកម្មនៃការពិឃាតរង្គាល វិនាសកម្ម និងភេរវកម្ម (Terrorism) ដោយធ្វើយុទ្ធនាការទម្លាក់គ្រាប់បែក B-52 ចំនួន៣,៦៣០ដង ទៅលើប្រជាពលរដ្ឋខ្មែរ ពីឆ្នាំ១៩៦៩ទៅដល់ឆ្នាំ១៩៧០ ។

សូមអានអត្ថបទមួយរបស់លោក Jussi Hanhimäki ៖

«តាំងពីរដូវប្រាំង (១៨មិនា) នៃឆ្នាំ១៩៦៩ ប្រទេសកម្ពុជាបានទទួលសេចក្ដីខ្លោចផ្សារ ដោយអាមេរិកាំងធ្វើយុទ្ធនាការទម្លាក់គ្រាប់បែក លាតសន្ធឹងកាន់តែវែងឆ្ងាយ ហើយក៏ប្រទាញប្រទេសនេះ ចូលកាន់តែជ្រៅទៅៗក្នុងភ្លក់ភ្លើងសង្គ្រាមវៀតណាម ។ បើទោះជាយ៉ាងនេះក្ដី, សម្ដេចសីហនុនៅតែចង់រក្សាមិត្តភាពល្អពីខាងក្រៅជាមួយនិងសហរដ្ឋអាមេរិកដដែល ក្នុងប្រការដែលទ្រង់ត្រូវការរកជំនួយពីខាងក្រៅ ដើម្បីទប់ទល់នឹងពួកយៀកណាមខាងជើង ។ ហេតុដូច្នេះទ្រង់ក៏បាន, ទោះដោយចំពោះក្ដី, បញ្ជាក់ថាទ្រង់មិនប្រឆាំងនឹងអាមេរិកាំង ដែលប្រដេញតាមពួកយៀកណាមខាងជើងនៅប្រទេសកម្ពុជានោះឡើយ ។ បើទោះជារឿងនេះ មានសេចក្ដីថាទ្រង់មិនមែនរង់ចាំ ឬក៏មានសេចក្ដីសប្បាយចិត្តនឹងឃើញនោះក៏ដោ-យ គឺយុទ្ធនាការទម្លាក់គ្រាប់បែកលាតសន្ធឹងទៅលើកម្ពុជា រវាងឆ្នាំ១៩៦៩និងឆ្នាំ១៩៧០... អាកប្បកិរិយាមិននិយាយស្ដីរបស់សម្ដេច គឺបានណែនាំឲ្យគីស្ស៊ីងគ្ញើរយល់ថា សីហនុបាន«យល់ព្រម»ឲ្យមានការទម្លាក់គ្រាប់បែកទាំងនេះ» ( The Flawed Architect, p.71)...

★★★ ទាក់ទងនឹងពាក្យឃ្លាចុងក្រោយនៃអត្ថបទខាងលើនេះ យើងបានស-ង្កេតឃើញថា ៖

ក- សីហនុមិនមែន «មានអាកប្បកិរិយាមិននិយាយមិនស្ដី»នោះទេ គឺព្រះប្រមុខរដ្ឋខ្មែរបាននិយាយពេញមាត់ ដើម្បីឲ្យអាមេរិកាំងយល់ច្បាស់ អំពីគោលបំណងរបស់ព្រះអង្គ ដែលចង់ឲ្យមានការទម្លាក់គ្រាប់បែកអ៊ុយអែសទៅលើប្រទេសកម្ពុជា ។ នៅដើមឆ្នាំ១៩៦៩ សម្ដេចសីហនុបានយកផែនទីសម្ងាត់របស់កងយោធាខ្មែរ ដែលមានបង្ហាញអំពីជំរំទីតាំងយៀកកុង នៅជួរព្រំប្រទល់ខាងកើត ទៅលាត

ត្រដាងនៅចំពោះមុខពួកអ្នកសារពត៌មានអន្តរជាតិ (ជាពិសេសមាន Jean Barré ភ្នាក់ងារពត៌មានបារាំង, Bernard Hamel តំណាងវីទែរ...) ។ នៅពេលនោះ សម្តេចបានថ្លែងប្រាប់ភ្នាក់ងារពត៌មានបារាំងថា ៖ «ខ្ញុំលែងទ្រាំទ្រចំពោះការរុករុល នៃទ័ពយៀកកុងនិងយៀកណាមខាងជើងចូលក្នុងដីខ្មែរទៀតហើយ ។ ក្នុងប្រការនេះ បើអាមេរិកាំងធ្វើការទម្លាក់គ្រាប់បែក នៅទីកន្លែងណាដាច់ស្រយាល ដែលពុំមានប្រជាជនខ្មែររស់នៅ ក្នុងព្រំប្រទល់របស់យើង, នោះខ្ញុំគ្មានយោបល់ជំទាស់ទេ» ។ នែហ៍ ! វាអីចេះទៅទៀត... តើវាមានដីខ្មែរឯណាដែលឥតមានខ្មែរនៅនោះ ?

ខ- មិនមែនមានត្រឹមតែវាចាប៉ុណ្ណោះទេ គឺមានទង្វើថែមទៀត ។ សីហនុបានដាក់ឲ្យមានឋានទូតអាមេរិកាំងឡើងវិញនៅភ្នំពេញ ខែមិថុនា១៩៦៩ គឺចំពេលដែលយន្តហោះ B-52 អាមេរិកាំងកំពុងតែទម្លាក់គ្រាប់បែកពេញទំហឹងលើទឹកដីប្រទេសកម្ពុជា ។ ពាក្យឃោសនាខាងក្រៅថា ការដាក់ទូតឡើងវិញ គឺមកពីអាមេរិកាំងទទួលស្គាល់ព្រំប្រទល់នៃកម្ពុជាបច្ចុប្បន្ន ។ តាមពិតអាមេរិកាំងក៏ដូចតែយៀកកុងហើយនិងយួនខាងជើង គឺទទួលស្គាល់ព្រំដែនកម្ពុជារួចហើយ ក៏ធ្វើការបំពារបំពានបូរណភាពទឹកដីតែម្តង ។ នេះមិនគឺសីហនុកំពុងតែឃុបឃិតជាមួយនឹងគីស្សីងគ្ញើរ ដើម្បីរុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់ចូលក្នុងសង្គ្រាមអាមេរិកាំងទេឬ ??

គ- នៅថ្ងៃទី១៦សីហា១៩៦៩ សីហនុបានតែងតាំងឧត្តមសេនិយលន់-នល់ជានាយករដ្ឋាភិបាល«ស្រោចស្រង់ជាតិ» ដើម្បីស្រោចស្រង់ខ្មែរពីការឡោមព័ទ្ធរបស់យៀកកុង ។ នេះមិនគឺនយោបាយកំប្លុកកំប្លែង ដែលស្តេចសីហនុរៀបចំធ្វើការ«ទម្លាក់ខ្លួនឯង»ទេឬ ? ។ គឺសីហនុកំពុងតែរៀបចំលាបពណ៌ឧត្តមសេនិយលន់-នល់ ឲ្យទៅជាស្តាំនិយម ប្រូអាមេរិកាំង ឲ្យទៅជាស៊ូហារតូ (!!) ។ គឺសីហនុកំពុងតែបង្កើត«ជនក្បត់» ដើម្បីអនុញ្ញាតឲ្យខ្លួនឯង មានលេសរត់ទៅធ្វើស្តេចយៀកកុងនៅប៉េកាំង ។ ពីព្រោះថា បើគ្មាន«ជនក្បត់»ទេ ធ្វើម្តេចឡើយសីហនុនឹងអាចក្លាយទៅជា«ព្រះបាទធម្មិក» ឬក៏ទៅជា«ស្តេចសតូចស្តើងសោយរាជ្យនគរបី» ?? ។

★★★ ដូច្នេះ, យោងតាមព្រឹត្តិការណ៍ទាំងអស់ខាងលើនេះ គឺស្តេចសីហនុហើយនិងគីស្សីងគ្ញើរ ដែលបានរួមគំនិតគ្នាក្នុងឆ្នាំ១៩៦៩-១៩៧០ ក្នុងប្រការលេងល្បែងកំប្លុកកំប្លែងនៃ«ការទម្លាក់ស្តេចសីហនុ» ស្របគ្នានឹងរគោលការណ៍របស់ហូជីមិញ-ផាំយ៉ាំងដុង ដើម្បីធ្វើឲ្យទឹកដីខ្មែរក្លាយជាទឹកដីយួន, ហើយក៏លើកឧក្រិដ្ឋកម្មប្រកបដោយទម្ងន់ធ្ងន់ដូចប្រថពីនេះ ទៅលាបប្រឡាក់ឧត្តមសេនិយលន់-នល់ និងទ្រង់សិរិមត:...

★★★ ដូច្នេះ គឺបនសីហនុ-គីស្សីងគ្ញើរនេះហើយ ដែលគេត្រូវប្រអូសប្រទាញយកមកកាត់ទោស អំពីបទប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា... ជាមួយនឹ

ងបនមេដឹកនាំឃ្មួនសព្វថ្ងៃ  ហើយជាមួយនិងបនខ្មែរក្រហមប៉ុលពត-អៀងសារី ដោយតុលាការអព្យាក្រឹត្យ នៅក្នុងពេលខាងមុខនេះ ។៚

⌘ ⌘

⌘